# ព្រះរាជក្រម

នស/រកម/០៣២៥/ 00៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

រដ្ឋសភា
ចូល
លេខ.......
ថ្ងៃទី....... ឆ្នាំ២០២....... ម៉ោង.......
បញ្ជូនទៅ.......

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៥ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៧ ហើយដែលព្រឹទ្ធសភាបានពិនិត្យបានបញ្ចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៥ នាសម័យប្រជុំព្រឹទ្ធសភា [illegible] នីតិកាលទី៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

# ច្បាប់
# ស្តីពី
# ការចាត់ចែងជាបណ្តោះអាសន្ន
# នូវវត្ថុចាប់យក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា១ .. គោលបំណង

ច្បាប់នេះ កំណត់អំពីលក្ខខណ្ឌ សមត្ថកិច្ច និងនីតិវិធីក្នុងការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ ក្នុងគោលបំណងរក្សាតម្លៃសេដ្ឋកិច្ចនៃវត្ថុចាប់យកទាំងនោះ ព្រមទាំងការពារផលប្រយោជន៍របស់ម្ចាស់នៃវត្ថុចាប់យក ឬរបស់បុគ្គលពាក់ព័ន្ធផ្សេងទៀត និងការពារផលប្រយោជន៍សាធារណៈ។

### មាត្រា២ .. វិសាលភាព

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះវត្ថុទាំងអស់ដែលត្រូវបានចាប់យកនៅគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។

### មាត្រា៣ .. និយមន័យ

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ៖

- **ការចាត់ចែងជាបណ្ដោះអាសន្ន** សំដៅដល់ការលក់ឡាយឡុងនូវវត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន ឬការចាត់ចែងក្នុងទម្រង់ណាមួយផ្សេងទៀតក្រៅពីការលក់ឡាយឡុង តាមការកំណត់ក្នុងច្បាប់នេះ នៅមុនពេលមានការសម្រេចនៅក្នុងសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ
- **ម្ចាស់ករណី** សំដៅដល់អង្គភាពនគរបាលយុត្តិធម៌ ឬមន្ត្រីនគរបាលយុត្តិធម៌ ដែលបានធ្វើប្រតិបត្តិការក្នុងការចាប់នូវវត្ថុចាប់យក
- **វត្ថុចាប់យក** សំដៅដល់វត្ថុតាងឬវត្ថុដទៃទៀតដែលត្រូវបានចាប់យក ឬឃាត់ទុក ឬបង្កកនៅគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងរឿងក្ដីព្រហ្មទណ្ឌ
- **បុគ្គលពាក់ព័ន្ធ** សំដៅដល់បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងវត្ថុចាប់យក ជាអាទិ៍ម្ចាស់វត្ថុ ឬបុគ្គលដែលពាក់ព័ន្ធនឹងដំណើរការរឿងក្ដីព្រហ្មទណ្ឌ។

## ជំពូកទី ២
## លក្ខខណ្ឌក្នុងការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក

### មាត្រា៤ .. វត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន

វត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្ន មានដូចខាងក្រោម៖

១-វត្ថុដែលគុណភាពរបស់វាមិនអាចរក្សាទុកបានយូរ ឬដែលអាចខូចខាតភ្លាមៗ។

២-វត្ថុដែលការរក្សាទុករយៈពេលវែងធ្វើឱ្យបាត់បង់បរិមាណ ឬខូចគុណភាព។

៣-វត្ថុដែលការរក្សាទុករយៈពេលវែងបណ្ដាលឱ្យចុះតម្លៃសេដ្ឋកិច្ចច្រើន។

៤-វត្ថុដែលត្រូវការសោហ៊ុយច្រើនដើម្បីរក្សាទុក។

៥-វត្ថុដែលគ្មានបុគ្គលណាទាមទារ ក្រោយរយៈពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃចាប់យក។

៦-វត្ថុដែលគ្មានបុគ្គលណាមកទទួលយក បន្ទាប់ពីមានសេចក្ដីសម្រេចប្រគល់ជូនបុគ្គលនោះ ក្រោយរយៈពេល ៦ (ប្រាំមួយ) ខែ គិតពីថ្ងៃជូនដំណឹងជាសាធារណៈ។

៧-វត្ថុដែលត្រូវបានចាប់យក ប៉ុន្តែពុំមានសេចក្ដីសម្រេចណាមួយរបស់តុលាការដែលចាត់ចែងលើវត្ថុនោះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

វត្ថុចាប់យកដែលមានចែងខាងលើនេះ អាចជាវត្ថុតាងឬវត្ថុដទៃទៀតដែលត្រូវបានចាប់យកនៅគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។

## មាត្រា៥.- លក្ខខណ្ឌនៃការចាត់ចែងជាបណ្តោះអាសន្ន

ការចាត់ចែងជាបណ្តោះអាសន្ន អាចធ្វើបានចំពោះវត្ថុចាប់យកដែលបានបំពេញលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា៤ (វត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន) នៃច្បាប់នេះ។ ការប្រើប្រាស់វិធានការនៃការចាត់ចែងជាបណ្តោះអាសន្ននេះ អាចធ្វើទៅបានក្នុងលក្ខខណ្ឌដែលវិធានការនេះពុំបង្កជាឧបសគ្គដល់ការសម្តែងឱ្យឃើញការពិត នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ។ ការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ត្រូវធ្វើទៅលើវត្ថុដែលអាចជាកម្មវត្ថុនៃការរឹបអូស ឬត្រូវធ្វើឡើងដើម្បីការពារផលប្រយោជន៍របស់ម្ចាស់វត្ថុ ឬរបស់បុគ្គលពាក់ព័ន្ធផ្សេងទៀត ឬដើម្បីការពារផលប្រយោជន៍សាធារណៈ។

ការចាត់ចែងជាបណ្តោះអាសន្នមិនអាចធ្វើបានឡើយ ប្រសិនបើវត្ថុដែលចាប់យកនោះត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។ ការប្រគល់វត្ថុដែលចាប់យកឱ្យទៅម្ចាស់ដើមវិញ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។ ប៉ុន្តែ ចំពោះវត្ថុចាប់យកដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ទ្រព្យសម្បត្តិ ឬបរិស្ថាន ព្រមទាំងវត្ថុដែលមិនអាចកាន់កាប់បានដោយស្របច្បាប់ដោយបុគ្គលឯកជន ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬត្រូវបំផ្លាញចោល។ ការសម្រេចអំពីការបំផ្លាញចោលនូវវត្ថុទាំងនេះ ជាសមត្ថកិច្ចរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ អាស្រ័យទៅតាមដំណាក់កាលនីមួយៗនៃនីតិវិធីដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។

# ជំពូកទី ៣
# សមត្ថកិច្ច និងនីតិវិធីក្នុងការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក

## មាត្រា៦.- ការចាត់ចែងជាបណ្តោះអាសន្ននៅដំណាក់កាលអយ្យការ

ព្រះរាជអាជ្ញា មានសមត្ថកិច្ចក្នុងការចាត់ចែងជាបណ្តោះអាសន្ន នៅក្នុងដំណាក់កាលស៊ើបអង្កេតចំពោះវត្ថុចាប់យក ដូចមានចែងក្នុងចំណុចទី១ និងចំណុចទី២ នៃមាត្រា៤ (វត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន) នៃច្បាប់នេះ។ ព្រះរាជអាជ្ញាក៏មានសមត្ថកិច្ចផងដែរ ក្នុងការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកដែលមានចែងក្នុងចំណុចទី៦ និងចំណុចទី៧ នៃមាត្រា៤ (វត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន) នៃច្បាប់នេះ ក្នុងករណីដែលមិនមានសេចក្តីសម្រេចណាមួយដែលត្រូវបានធ្វើលើវត្ថុចាប់យក ទាំងក្នុងដំណាក់កាលស៊ើបសួរ ទាំងក្នុងដំណាក់កាលជំនុំជម្រះ។

ព្រះរាជអាជ្ញាសម្រេចចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកដោយឯកឯង ឬតាមការស្នើសុំរបស់អង្គភាពនគរបាលយុត្តិធម៌ដែលជាម្ចាស់ករណី ឬបុគ្គលពាក់ព័ន្ធ តាមរយៈដីកាសម្រេច។ បុគ្គលពាក់ព័ន្ធមានសិទ្ធិប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកាសម្រេច។

ប្រសិនបើមានការស្នើសុំឱ្យចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក ព្រះរាជអាជ្ញាត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ៥ (ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលការស្នើសុំ។ ក្នុងករណីមិនមានសេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃ អ្នកស្នើសុំអាចធ្វើបណ្តឹងសុំ ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលនឹងសម្រេចជំនួសព្រះរាជអាជ្ញានៃសាលាដំបូង។

នៅក្នុងគ្រប់ករណីទាំងអស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានបណ្តឹងសុំឬបណ្តឹងតវ៉ា។ ការសម្រេចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ បែបបទនៃការប្តឹងតវ៉ានេះ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងករណីបន្ទាន់ដែលវត្ថុចាប់យកអាចខូចខាតភ្លាមៗដូចមានចែងក្នុងចំណុចទី១ នៃមាត្រា៤ (វត្ថុចាប់យកដែលអាចជាកម្មវត្ថុនៃការចាត់ចែងជាបណ្តោះអាសន្ន) នៃច្បាប់នេះ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យនគរបាលយុត្តិធម៌ ធ្វើការចាត់ចែងជាបណ្តោះអាសន្នបាននូវវត្ថុចាប់យកនោះ។ ព្រះរាជអាជ្ញាត្រូវផ្តល់ការណែនាំចាំបាច់នានាសម្រាប់ការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននេះ។ នគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសឱ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុអំពីការអនុញ្ញាតឱ្យចាត់ចែងជាបណ្តោះអាសន្នរបស់ព្រះរាជអាជ្ញា។

## មាត្រា៧ .- ការចាត់ចែងជាបណ្តោះអាសន្ននៅដំណាក់កាលស៊ើបសួរ

ចៅក្រមស៊ើបសួរមានសមត្ថកិច្ចក្នុងការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនៅក្នុងដំណាក់កាលស៊ើបសួរ។

ចៅក្រមស៊ើបសួរសម្រេចចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកដោយឯកឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬតាមការស្នើសុំរបស់បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងវត្ថុចាប់យក។

ប្រសិនបើមានការស្នើសុំឱ្យចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកដូចមានចែងក្នុងកថាខណ្ឌទី២ខាងលើ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ៥ (ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំតាមដីកាសម្រេចដែលត្រូវជូនដំណឹងដល់អ្នកស្នើសុំ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេល៥ (ប្រាំ)ថ្ងៃ អ្នកស្នើសុំអាចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរនោះ។ សភាស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល១៥ (ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានបណ្តឹងឧទ្ធរណ៍។ ការសម្រេចរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ បែបបទនៃការប្តឹងឧទ្ធរណ៍នេះ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មុននឹងចៅក្រមស៊ើបសួរធ្វើការសម្រេចអំពីការចាត់ចែងជាបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវទទួលបានយោបល់របស់ព្រះរាជអាជ្ញា លើកលែងតែក្នុងករណីដែលព្រះរាជអាជ្ញា ជាអ្នកស្នើសុំឱ្យចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនោះ។ ព្រះរាជអាជ្ញា ត្រូវបញ្ជូនយោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងយូរ ៤៨(សែសិបប្រាំបី)ម៉ោង បន្ទាប់ពីទទួលបានដីកាបញ្ជូនឱ្យឆ្លើយរបស់ចៅក្រមស៊ើបសួរ។

ព្រះរាជអាជ្ញា ឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធ មានសិទ្ធិប្តឹងឧទ្ធរណ៍ទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ក្នុងរយៈពេល៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកាសម្រេច។ បណ្តឹងឧទ្ធរណ៍នេះមានអានុភាពផ្អាកការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកនេះ។ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានបណ្តឹងឧទ្ធរណ៍។ ការសម្រេចរបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា។ បែបបទនៃការប្តឹងឧទ្ធរណ៍នេះ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## មាត្រា៨ .- ការចាត់ចែងជាបណ្តោះអាសន្ននៅដំណាក់កាលជំនុំជម្រះ

ចៅក្រមជំនុំជម្រះ មានសមត្ថកិច្ចក្នុងការចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យក នៅក្នុងដំណាក់កាលជំនុំជម្រះ។ នៅពេលដែលវត្ថុចាប់យកត្រូវបានសម្រេចរឹបអូសជាទ្រព្យសម្បត្តិរបស់រដ្ឋ ចៅក្រមជំនុំជម្រះអាចសម្រេចចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុនេះ។ ការសម្រេចនេះត្រូវធ្វើជាមួយគ្នានៅក្នុងសាលក្រមដែលសម្រេចលើអង្គសេចក្តី។

ក្នុងករណីចាំបាច់ តាមការស្នើសុំរបស់ព្រះរាជអាជ្ញាឬតាមការស្នើសុំរបស់បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងវត្ថុចាប់យក ចៅក្រមជំនុំជម្រះអាចសម្រេចចាត់ចែងជាបណ្តោះអាសន្ននូវវត្ថុចាប់យកមុនការ

សម្រេចលើអង្គសេចក្ដីបានតាមសាលក្រម។ ព្រះរាជអាជ្ញា ឬបុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធមានសិទ្ធិប្ដឹងឧទ្ធរណ៍ ក្នុងរយៈពេល៥ (ប្រាំ) ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីសាលក្រម។ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានបណ្ដឹងឧទ្ធរណ៍។ ការសម្រេចរបស់សាលាឧទ្ធរណ៍ជាសេចក្ដីសម្រេចបិទផ្លូវតវ៉ា។ បែបបទនៃការប្ដឹងឧទ្ធរណ៍នេះ ត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ជាបដិប្បញ្ញត្តិទៅនឹងបទប្បញ្ញត្តិស្ដីពីអានុភាពនៃបណ្ដឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម នៃក្រមនីតិវិធីព្រហ្មទណ្ឌ រយៈពេលសម្រាប់ប្ដឹងឧទ្ធរណ៍ និងការប្ដឹងឧទ្ធរណ៍ ចំពោះការសម្រេចចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក មិនមែនជាឧបសគ្គដល់ការអនុវត្តលើការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកឡើយ។

## មាត្រា៩ .. ការជូនដំណឹង

ការជូនដំណឹងទៅបុគ្គលពាក់ព័ន្ធអំពីការសម្រេចចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ត្រូវផ្សព្វផ្សាយជាសាធារណៈតាមសារព័ត៌មាន និងត្រូវបិទផ្សាយនៅបញ្ជរបិទផ្សាយព័ត៌មានរបស់សាលាដំបូង និងត្រូវផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់សាលាដំបូង។ ការផ្សព្វផ្សាយព័ត៌មាននេះ ត្រូវជូនដំណឹងមកក្រសួងយុត្តិធម៌ ដើម្បីផ្សព្វផ្សាយបន្ត។ ទន្ទឹមនឹងការជូនដំណឹងដូចមានចែងក្នុងវាក្យខណ្ឌទី១ ខាងលើ ការជូនដំណឹងត្រូវធ្វើដោយផ្ទាល់បន្ថែមទៅបុគ្គលពាក់ព័ន្ធ ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងករណីដែលអត្តសញ្ញាណរបស់បុគ្គលពាក់ព័ន្ធត្រូវបានគេស្គាល់។

ក្នុងករណីចាំបាច់ ក្រសួងយុត្តិធម៌អាចចេញសេចក្ដីណែនាំបន្ថែមអំពីវិធីផ្សព្វផ្សាយជាសាធារណៈ។

## មាត្រា១០ .. អ្នកជំនាញក្នុងការវាយតម្លៃអំពីវត្ថុចាប់យក

ក្នុងករណីចាំបាច់ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះដែលមានសមត្ថកិច្ច អាចស្នើសុំឱ្យអ្នកជំនាញឬស្ថាប័នជំនាញណាមួយ ដើម្បីធ្វើការវាយតម្លៃអំពីវត្ថុចាប់យកបាន មុននឹងធ្វើការសម្រេចអំពីការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក។

ក្រសួងយុត្តិធម៌អាចចេញសេចក្ដីណែនាំអំពីលក្ខខណ្ឌនិងបែបបទនៃការជ្រើសរើសអ្នកជំនាញឬស្ថាប័នជំនាញ។

## មាត្រា១១ .. ទម្រង់ បែបបទ និងនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន

ការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនេះ ត្រូវធ្វើក្នុងទម្រង់ជាការលក់ឡាយឡុង។ បែបបទនិងនីតិវិធីនៃការលក់ឡាយឡុងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណីចាំបាច់ ការចាត់ចែងជាបណ្ដោះអាសន្ន អាចធ្វើក្នុងទម្រង់ផ្សេងក្រៅពីការលក់ឡាយឡុង។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចេញប្រកាសដើម្បីកំណត់អំពីបែបបទនិងនីតិវិធីក្នុងការអនុវត្ត។

ក្នុងការសម្រេចចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនេះ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះដែលមានសមត្ថកិច្ច អាចសម្រេចប្រគល់វត្ថុនេះទៅឱ្យអ្នកស្នើសុំ ក្នុងករណីដែលម្ចាស់វត្ថុ ឬអ្នកកាន់កាប់វត្ថុ ឬតំណាងស្របច្បាប់ បានស្នើសុំដាក់ប្រាក់តម្កល់ជំនួសឱ្យការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យកនេះដោយការលក់តាមតម្លៃទីផ្សារជាក់ស្ដែង។

ការអនុវត្តលើការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក តាមដីកាសម្រេចរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ឬតាមសាលក្រម ឬសាលដីការបស់តុលាការ ជាសមត្ថកិច្ចរបស់គណៈកម្មការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន ដែលត្រូវបង្កើតឡើងនៅតាមសាលាដំបូងនីមួយៗដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា១២ .- សមត្ថកិច្ចដោះស្រាយការលំបាក**

រាល់ការលំបាកទាំងឡាយដែលពាក់ព័ន្ធនឹងការចាត់ចែងជាបណ្ដោះអាសន្ននូវវត្ថុចាប់យក ត្រូវលើកជូនប្រធានសាលាដំបូងដែលមានសមត្ថកិច្ចដែនដីដោះស្រាយ។

**មាត្រា១៣ .- ការចាត់ចែងប្រាក់តម្កល់**

ប្រាក់ដែលបានមកពីការលក់វត្ថុចាប់យកនិងប្រាក់ដែលត្រូវបានដាក់តម្កល់នៅក្នុងនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវតម្កល់ទុកនៅក្នុងគណនីធនាគារណាមួយ ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការចាត់ចែងប្រាក់តម្កល់ទុកនេះ ត្រូវអនុវត្តស្របតាមច្បាប់ សេចក្ដីសម្រេចរបស់តុលាការ និងបទប្បញ្ញត្តិជាធរមានផ្សេងទៀត។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា១៤ .- និរាករណ៍**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .- ការប្រកាសឱ្យប្រើ**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៣ កើត ខែ ផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២៥

៣សរ. ៧៥០៣. ៣៧១

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

វង្សី វិស្សុត